**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...០១១.......សហវ

## សារាចរ
## ស្តីពី
## ការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែម

អនុលោមតាមបទប្បញ្ញត្តិនៃជំពូកទី២ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងប្រកាសលេខ១១៧៣ សហវ.ពដ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់បៀវត្ស ដើម្បីលើកកម្ពស់ជីវភាពរស់នៅនិងការប្រកបការងារប្រចាំថ្ងៃរបស់កម្មករនិយោជិត នៃរោងចក្រ សហគ្រាសទាំងអស់ ប្រាក់ឧបត្ថម្ភមួយចំនួនដែលកម្មករនិយោជិតទទួលបានពីការបំពេញការងារ ត្រូវបានអនុគ្រោះដោយមិនគិតបញ្ចូលទៅក្នុងមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស និងមិនមែនជាកម្មវត្ថុនៃពន្ធលើអត្ថប្រយោជន៍បន្ថែមទេ។ ប្រាក់ឧបត្ថម្ភទាំងនោះមានដូចខាងក្រោម÷

១. សោហ៊ុយធ្វើដំណើរពីទីកន្លែងស្នាក់នៅទៅទីកន្លែងធ្វើការ និងពីទីកន្លែងធ្វើការទៅកន្លែងស្នាក់នៅ ព្រមទាំងការឧបត្ថម្ភថ្លៃស្នាក់នៅឬការផ្តល់កន្លែងស្នាក់នៅក្នុងបរិវេណទីកន្លែងធ្វើការ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ការងារ។

២. ប្រាក់ថ្លៃបាយដែលផ្តល់ឱ្យកម្មករនិយោជិតទាំងអស់ដោយគ្មានបែងចែកតាមតួនាទីឬមុខងារ។

៣. មូលនិធិបេឡាសន្តិសុខសង្គមឬមូលនិធិសុខមាលភាពសង្គមក្នុងកម្រិតដែលបានបញ្ញត្តិក្នុងច្បាប់។

៤. ប្រាក់ធានារ៉ាប់រងសុខភាពឬបុព្វលាភធានារ៉ាប់រងអាយុជីវិតឬសុខភាពដែលផ្តល់ឱ្យដល់កម្មករនិយោជិតគ្រប់គ្នាដោយគ្មានការបែងចែកតាមតួនាទីឬមុខងារ។

៥. ប្រាក់ឧបត្ថម្ភទារកឬចំណាយទារកដ្ឋាន ដែលមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ការងារ។

៦. ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាឬប្រាក់បំណាច់នៃការបញ្ឈប់លែងឱ្យធ្វើការ ក្នុងកម្រិតដែលបានបញ្ញត្តិក្នុងច្បាប់ការងារ។

ដើម្បីទទួលបានការអនុគ្រោះខាងលើនេះ រោងចក្រ សហគ្រាស ត្រូវដាក់ជូនអគ្គនាយកដ្ឋានពន្ធដារនូវឯកសារដែលជាគោលនយោបាយឧបត្ថម្ភដល់កម្មករនិយោជិតរបស់ខ្លួន សម្រាប់រយៈពេលកំណត់នីមួយៗ។

សារាចរនេះត្រូវបានដាក់ឱ្យប្រើប្រាស់ជំនួសសារាចរណែនាំលេខ ០០២ សហវ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម។

ទទួលបានសារាចរនេះ អគ្គនាយកដ្ឋានពន្ធដារ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គ្រប់រោងចក្រ សហគ្រាស ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាពនិងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798